


**Khmer**

ខ្យល់ព្យុះអាចជាគ្រោះថ្នាក់ធំមួយ។

ខ្យល់ព្យុះអាចមានខ្យល់ខ្លាំង, ភ្លៀងធំ, ផ្លេកបន្ទោរនិងព្រិល។

ភ្លៀងធំអាចបណ្តាលឲ្យមានទឹកជន់លិចមួយរំពេច។ តំបន់ដែលនៅទាបអាចមានទឹកជន់លិចដោយគ្មានការព្រមានឡើយ។

សូមស្តាប់ការព្រមានអំពីខ្យល់ព្យុះ។ សូមធ្វើឲ្យប្រាកដថាមិត្តភក្តិ, គ្រួសារនិងអ្នកជិតខាងដឹងអំពីការព្រមាននេះ។

ប្រសិនបើបើកបរ, សូមឈប់ដោយសុវត្ថិភាព, នៅឆ្ងាយពីចរាចរ។ សូមបើកភ្លើងអាសន្នរបស់រថយន្តលោកអ្នកហើយរង់ចាំខ្យល់ព្យុះកន្លងផុតទៅ។

**សូមកុំ**ចតរថយន្តលោកអ្នកនៅក្រោមដើមឈើ។ ដើមឈើនិងមែកវាអាចបាក់ធ្លាក់ក្នុងអម្លុងពេល ខ្យល់ព្យុះ។

ប្រសិនបើនៅខាងក្រៅ, សូមស្វែករកជម្រកនៅក្នុងអាគារផ្សេងៗ។ **សូមកុំ**ជ្រកនៅក្រោមដើមឈើ។

សូមចងឲ្យបានជាប់ល្អនូវរបស់រាត់រាយនៅក្នុងសួនច្បារ ឬនៅជុំវិញផ្ទះរបស់លោកអ្នក។

ប្រសិនបើនៅខាងក្នុង, សូមនៅឲ្យឆ្ងាយពីបង្អួច។

សូមបើកវិទ្យុ ABC ឬស្ថានីយវិទ្យុតំបន់របស់លោកអ្នកសំរាប់ការព្រមានភាពអាសន្ននិងឱវាទ។

សូមរៀបចំផែនការនៃភាពអាសន្ននៅក្នុងផ្ទះសំរាប់ផ្ទះនិងពាណិជ្ជកម្មរបស់លោកអ្នក។

សូមរៀបចំគ្រឿងសំរាប់ភាពអាសន្នដែលមានដូចជា:
- ឯកសារសំខាន់ៗ(លិខិតឆ្លងដែន/ទិដ្ឋាការ, សំបុត្រទិញថ្នាំពេទ្យជាដើម)
- វិទ្យុដែលប្រើថ្មពិល
- ប្រអប់ជំនួយព្យាបាលដំបូងFirst Aid Kit
- ពិល
- រូបថតនិងអត្តសញ្ញាណប័ណ្ណ។

ជំនួយភាពអាសន្ននៃការជន់លិចនិងខ្យល់ព្យុះ សូមទូរស័ព្ទលេខ 132 500។

ភាពអាសន្នដែលគំរាមកំហែងដល់ជីវិត សូមទូរស័ព្ទលេខ 000។

ប្រសិនបើលោកអ្នកត្រូវការជម្លៀសចេញ, សូមយកគ្រឿងសំរាប់ភាពអាសន្នទៅតាមខ្លួនផង។

**សូមកុំ**បើកបរ, ជិះ ឬដើរនៅក្នុងទឹកជំនន់ឲ្យសោះ។

**សូមកុំ**ឲ្យក្មេងលេងនៅក្នុងទឹកជំនន់ឲ្យសោះ។ វាក្រខ្វក់ហើយគ្រោះថ្នាក់ទៀតផង។

ពេលខ្យល់ព្យុះបានកន្លងផុតទៅ, សូមប្រាប់អ្នកដែលស្គាល់លោកអ្នកឲ្យដឹងថាលោកអ្នកមិនអីទេ។